# មេរៀនទី ១៣១: ដាវីឌក្លាយទៅជាស្តេច

## ២សាំយូអែល ៥:១-៥ ទំនុកតម្កើង៣៧

**គោលបំណង៖** ព្រះគួរជាទីទុកចិត្ត។

**ខគម្ពីរចងចាំ៖ សុភាសិត ៣:៥-៦** *“ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងដំរង់អស់ទាំងផ្លូវច្រករបស់ឯង។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

តាមរយៈព្រះយេស៊ូវ ព្រះបានបង្ហាញយើងពីរបៀបដែលយើងអាច ពឹងផ្អែកលើទ្រង់គ្រប់ជំហាននៃជីវិតរបស់យើង។ ដោយសារភាពក្លាហានរបស់ព្រះយេស៊ូវយើងអាចជឿថាការទុកចិត្តលើព្រះនឹងមានតម្លៃជានិច្ច! តើព្រះប្រើអ្វីដើម្បីបង្រៀនអ្នកឥឡូវនេះអំពីការពឹងផ្អែកលើទ្រង់? សុំប្រាជ្ញាពីព្រះ ដើម្បីមើលឃើញនិងមានកម្លាំងដើម្បីឈានទៅមុខដោយសេចក្តីជំនឿ។ អ្នកអាចពឹងផ្អែកលើព្រះ ពីព្រោះទ្រង់មានអ្វីគ្រប់យ៉ាងដែលអ្នកត្រូវការ!

**ចំរៀង៖** ១. ស្តេចលើស្តេច ២. ខ្ញុំទុកចិត្តលើព្រះយេស៊ូវ ៣. ខ្ញុំនឹងទុកចិត្តទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «គួរឲ្យទុកចិត្ត ឬក៏មិនគួរឲ្យទុកចិត្ត»**

**សម្ភារៈដែលត្រូវការ៖** ដបទឹក២ដូចគ្នា(ដបមួយចោះរន្ធតូចមួយនៅផ្នែកខាងក្រោម) អាវភ្លៀង២ដូចគ្នា(ប៉ុន្តែមួយគឺរហែក) ប៊ិក២ដូចគ្នា(តែមួយប្រើមិនកើត)អ្វីមួយក៏បានដែលមួយអាចប្រើបាន ហើយមួយទៀតមិនអាចប្រើបាន







១. ចែកកុមារជា២ក្រុម។

២. ដាក់ដបទឹកទាំង២នៅចុងម្ខាងនៃថ្នាក់រៀន។

៣. អ្នកស្ម័គ្រចិត្តមកពីក្រុមទាំងពីរត្រូវរត់ទៅឯចុងម្ខាងនៃថ្នាក់រៀន ហើយយកដបទឹកមួយរួចរត់ត្រឡប់មករកគ្រូវិញ

៤. គ្រូនឹងពិនិត្យមើលដបទឹក ក្រុមណាដែលយកដបទឹកដែលគ្មានរន្ធមកឲ្យគ្រូនឹងទទួលបាន១ពិន្ទុ។

៥. លេងល្បែងនេះសារឡើងវិញ ដោយប្រើអាវភ្លៀង ប៊ិក និង របស់របរផ្សេងទៀតដែលមួយប្រើកើត ហើយមួយទៀតប្រើមិនកើត។

៦. គ្រូអាចឲ្យសិស្សលេងល្បែងនេះម្តងទៀតបានដោយប្រើសម្ភារៈដដែល។

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា សម្ភារៈទាំងអស់គឺមើលទៅដូចគ្នាបិះបិទ ប៉ុន្តែមួយប្រើកើតមួយទៀតប្រើមិនកើត។ ក្នុងនាមជាគ្រិស្តបរិស័ទ យើងតែងតែអាចទុកចិត្តលើព្រះបាន ដោយសារព្រះមានឫទ្ធានុភាព ហើយទ្រង់មិនដែលប្រែប្រួលឡើយ។

**៤. ការណែនាំមេរៀន**

តើតើអ្នកធ្លាប់ជិះឡានដែរឬទេ? នៅពេលដែលអ្នកជិះឡាន គឺអ្នកបានផ្ញើជីវិតលើអ្នកបើកឡាន។ តើអ្នកទុកចិត្តលើអ្នកបើកដែរឬទេ? តើអ្នកទុកចិត្តលើនរណានៅក្នុងជីវិតរបស់អ្នក? តើអ្នកអាចពឹងផ្អែកលើឪពុកម្តាយរបស់អ្នកបានដែរឬទេ? តើអ្នកអាចពឹងផ្អែកលើមិត្តរបស់អ្នកបានដែរឬទេ? តើអ្នកអាចពឹងផ្អែកលើមិត្តដែលតែងតែនិយាយកុហកអ្នកបានដែរឬទេ? តើអ្នកអាចពឹងផ្អែកលើមនុស្សដែលអ្នកមិនស្គាល់បានដែរឬទេ? ថ្ងៃនេះយើងនឹងរៀនថា យើងអាចពឹងផ្អែកលើព្រះជានិច្ច ពីព្រោះព្រះទ្រង់សប្បុរស មានប្រាជ្ញា និងសេចក្តីស្រឡាញ់ ហើយតែងតែធ្វើតាមការសន្យារបស់ទ្រង់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

កាលពីកុមារភាពដាវីឌគឺជាអ្នកគង្វាលចៀម។ ព្រះគម្ពីរបាននិយាយថាគាត់បានមើលថែ និងការពារសត្វចៀមបានយ៉ាងល្អ។ ដាវីឌបានពឹងផ្អែកលើព្រះក្នុងការជួយគាត់មើលថែចៀមទាំងអស់នោះ។ ព្រះបានផ្តល់ឲ្យគាត់នូវកម្លាំងនិងប្រាជ្ញា។ ព្រះគម្ពីរបានប្រាប់យើងថា ដាវីឌបានធំធាត់ឡើងដើម្បីធ្វើជាអ្នកចម្បាំង ។ គាត់បានបម្រើនៅក្នុងជួរកងទ័ព។ គាត់គឺជាទាហានដ៏ក្លាហាន។ គាត់បានប្រយុទ្ធជាមួយនឹងយក្សកូលីយ៉ាតដ៏ធំ ដោយគ្រាន់តែប្រើខ្សែ និងថ្មប៉ុណ្ណោះ។ ពេលខ្លះគាត់បានប្រយុទ្ធដោយប្រើធ្នូ និងព្រួញ។

ដាវីឌគឺជាអ្នកចម្បាំងដ៏ជោគជ័យម្នាក់ដោយសារគាត់ពឹងផ្អែកលើព្រះ។ ដាវីឌបានដឹងថាគាត់អាចទុកចិត្តព្រះដើម្បីជួយគាត់ឲ្យក្លាយជាអ្នកចម្បាំងដ៏ក្លាហាន។ សូម្បីតែពេលស្តេចសូលព្យាយាមសម្លាប់គាត់ ដោយសារការច្រណែនក៏ដាវីឌបានពឹងផ្អែកលើព្រះដើម្បីការពារគាត់ដែរ។

ថ្ងៃមួយ ស្តេចសូលក៏បានសោយទិវង្គតនៅក្នុងសមរភូមិ។ កូនចៅរបស់ស្តេចសូលទាំងអស់ក៏ស្លាប់ ក្នុងសមរភូមិដែរ។ ដូច្នេះ ដាវីឌក៏បានក្លាយជាស្តេចបន្ទាប់របស់សាសន៍អ៊ីស្រាអែល។ ដាវីឌត្រូវដឹកនាំប្រជាជនដោយប្រាជ្ញា។ គាត់ត្រូវតែបង្កើតច្បាប់ឲ្យបានល្អសម្រាប់ប្រជាជន។ ដាវីឌត្រូវធ្វើការសម្រេចចិត្តឱ្យបានល្អពីអ្វីដែលល្អបំផុតសម្រាប់ប្រទេសរបស់គាត់។

ដាវីឌបានពឹងលើព្រះដើម្បីជួយគាត់ឲ្យក្លាយជាស្តេចដ៏ល្អ។ គាត់បានដឹងថាគ្មានអ្នកណាដែលគាត់អាចទុកចិត្តបានក្រៅពីព្រះនោះទេ។ ស្តេចដាវីឌដឹងថាព្រះគួរឲ្យទុកចិត្ត និងអាចពឹងពាក់បាន។

នៅពេលដែលយើងនិយាយថា ព្រះជាម្ចាស់អាចពឹងពាក់បាននោះមានន័យថាទ្រង់រឹងមាំ ព្រះអង្គគួរឱ្យទុកចិត្ត ព្រះជាម្ចាស់នឹងជួយយើងជានិច្ច ហើយទ្រង់តែងតែល្អជានិច្ច។ ទ្រង់មានប្រាជ្ញាតែងតែស្រឡាញ់ ហើយព្រះអង្គនឹងថែរក្សាយើងជានិច្ចផងដែរ។

យើងអាចពឹងផ្អែកលើព្រះឲ្យជួយយើង ទោះបីជាយើងភ័យខ្លាចក៏ដោយ។ ពេលខ្លះព្រះជួយយើងដោយផ្តល់ភាពក្លាហានដល់យើង។ ជួនកាលព្រះជួយយើងដោយបញ្ជូនមនុស្សម្នាក់មកជួយដល់យើង។ ជួនកាលព្រះជួយយើងឱ្យដឹងពីរបៀបធ្វើអ្វីមួយ។ យើងអាចទុកចិត្តព្រះក្នុងការណែនាំយើង ដើម្បីបង្ហាញយើងពីផ្លូវត្រឹមត្រូវ ដោយសារព្រះជាទីទុកចិត្ត។ ចូរយើងធ្វើដូចស្តេចដាវីឌ ហើយពឹងផ្អែកលើព្រះដែលគួរជាទីទុកចិត្តរបស់យើង!

**៦. សំនួរពិភាក្សា**

១. តើនរណាដែលបានជួយដាវីឌឲ្យក្លាយជាអ្នកគង្វាលចៀមដ៏ល្អ? *ព្រះ*

២. តើនរណាដែលបានជួយដាវីឌឲ្យក្លាយជាអ្នកចម្បាំងដ៏ក្លាហាន? *ព្រះ*

៣. តើនរណាដែលបានជួយដាវីឌឲ្យក្លាយជាស្តេចដ៏ល្អ? *ព្រះ*

៤. តើដាវីឌពឹងពាក់លើនរណាក្នុងជីវិតរបស់គាត់? *ព្រះ*

៥. តើអ្នកអាចពឹងពាក់លើនរណាដើម្បីជួយអ្នកគ្រប់ផ្លូវទាំងអស់នៃដំណើរជីវិតរបស់អ្នក? *ព្រះ*

**៧. ល្បែងកំសាន្ត** «ស្តេចបញ្ជា»



១.ឲ្យកុមារឈរជាជួរ ហើយប្រុងប្រៀបក្នុងការស្តាប់គ្រូ។
២. ប្រសិនបើគ្រូនិយាយថា "ស្តេចបញ្ជាឲ្យ.." កុមារទាំងអស់ត្រូវតែធ្វើតាម។
៣. ប៉ុន្តែប្រសិនបើគ្រូមិនបាននិយាយពាក្យថា"ស្តេចបញ្ជា..."នោះកុមារមិនត្រូវធ្វើតាមគ្រូនោះទេ។ ឧទាហរណ៍៖ ប្រសិនបើគ្រូនិយាយថា "ស្តេចបញ្ជាឲ្យ ទះដៃ" ដូច្នេះកុមារទាំងអស់ត្រូវតែទះដៃ។
៤. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ស្តេចមានអំណាចក្នុងការបញ្ជាឲ្យមនុស្សធ្វើអ្វីក៏បាន។ យើងគួរតែមានភាពសប្បាយរីករាយ ពីព្រោះព្រះដែលជាស្តេចរបស់យើង ដែលអាចឲ្យយើងទុកចិត្តបាន ហើយបញ្ជាឲ្យយើងធ្វើនូវអ្វីដែលល្អត្រឹមត្រូវសម្រាប់ខ្លួនយើង។

**៨. ខគម្ពីរចងចាំ** សុភាសិត ៣:៥-៦

**៩. ហត្ថកម្ម** «ព្រះជាម្ចាស់ប្រៀបបាននឹងឆ័ត្រឥន្ទ»




**សម្ភារៈដែលត្រូវការ៖** ចានក្រដាស កន្ត្រៃ កូល័រ ការបិត និងក្រដាស
១. ឲ្យចានក្រដាសដែលបានកាត់ជាពីររួចទៅកុមារម្នាក់មួយ។
២.ឲ្យកុមារតុបតែងចានក្រដាសនោះ ហើយសរសេរពាក្យថា "ព្រះជាម្ចាស់ជាទីទុកចិត្ត" នៅចំកណ្តាល។ (សម្រាប់កុមារមួយចំនួនគ្រូអាចសរសេរជំនួសបាន។)
៣.ឲ្យកុមារកាត់ដងឆត្រ័ចេញមក ហើយបិតវាភ្ជាប់ជាមួយចានក្រដាស។
៤. (ជម្រើស) ប្រសិនបើកុមារចង់បាន ពួកគេអាចបង្កើតតំណក់ទឹកភ្លៀងដោយកាត់ក្រដាសស្តើងមួយ ហើយបិតរង្វង់ដើម្បីភ្ជាប់ទៅនឹងឆ័ត្រ។
៥. សូមពន្យល់កុមារថា យើងតែងតែអាចពឹងផ្អែកលើព្រះ ដើម្បីជួយយើងនិងការពារយើង សូម្បីតែពេលមានព្យុះភ្លៀងនៅក្នុងជីវិតរបស់យើងក៏ដោយ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*